**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ដែលសរសេរកាត់ថា **គ.ម.ជ** ដើម្បីលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ និងចូលរួមចំណែកអនុវត្តគោលនយោបាយជាតិកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

## ជំពូកទី២

## សមាសភាព

**មាត្រា ២.-**

**គ.ម.ច.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធានកិត្តិយស |
| ២- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១ រូប | អនុប្រធាន |
| ៥- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១ រូប | អនុប្រធាន |
| ៦- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១ រូប | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១ រូប | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១ រូប | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១ រូប | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១ រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងផែនការ ១ រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងព័ត៌មាន ១ រូប | សមាជិក |
| ១៥- អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ១ រូប | សមាជិក |
| ១៦- តំណាងកាកបាទក្រហមកម្ពុជា ១ រូប | សមាជិក |
| ១៧- តំណាងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ ១ រូប | សមាជិក |
| ១៨- ប្រធានលេខាធិការដ្ឋាននៃ **គ.ម.ច.** | ជាលេខាធិការ |

សមាសភាពជាក់ស្តែងរបស់ **គ.ម.ច.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## តួនាទីនិងភារកិច្ចរបស់ គ.ម.ច.

**មាត្រា ៣.-**

**គ.ម.ច.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយជាតិដើម្បីលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ឲ្យប្រសើរឡើង
- រៀបចំទិវាមនុស្សចាស់នៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់យកថ្ងៃទី១ ខែតុលា ជារៀងរាល់ឆ្នាំ រួមជាមួយនឹងទិវាមនុស្សចាស់អន្តរជាតិ

- សហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការជាតិ អង្គការអន្តរជាតិក្នុងនិងក្រៅប្រទេស ក្នុងវិស័យសុខុមាលភាពមនុស្សចាស់ និងសប្បុរសជននានាដើម្បីចូលរួមឧបត្ថម្ភគាំទ្រមនុស្សចាស់នៅកម្ពុជា
- លើកគម្រោងថវិកាជាតិសម្រាប់ដំណើរការការងាររបស់ **គ.ម.ច.**
- ជួយជំរុញនិងគាំទ្រសមាគមមនុស្សចាស់នៅតាមសហគមន៍
- គ្រប់គ្រងធនធានមនុស្សចាស់ប្រកបដោយប្រសិទ្ធភាពធានាបានការផ្ទេរចំណេះដឹង បទពិសោធការអនុវត្តល្អជាដើម ដល់អ្នកជំនាន់ក្រោយនិងសង្គមជាតិ
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ម.ច.

**មាត្រា ៤.-**

**គ.ម.ច.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៥.-**

**គ.ម.ច.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះយោបល់និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួនបាន។

**មាត្រា ៦.-**

**គ.ម.ច.** អាចមានទីប្រឹក្សាបច្ចេកទេសស្ម័គ្រចិត្តតាមការចាំបាច់ ដោយស្នើពីសមាគមមនុស្សចាស់នានានៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលក្នុងនិងក្រៅប្រទេស និងអង្គការអន្តរជាតិ។

**មាត្រា ៧.-**

បែបបទនិងនីតិវិធីការងាររបស់ **គ.ម.ច.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ម.ច.**។

**មាត្រា ៨.-**

**គ.ម.ច.** មានអនុគណៈកម្មាធិការដើម្បីមនុស្សចាស់នៅតាមរាជធានី ខេត្ត។

សមាសភាពនិងការរៀបចំនិងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការដើម្បីមនុស្សចាស់នៅតាមរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ម.ច.**។

**មាត្រា ៩.-**

**គ.ម.ច.** មានលេខាធិការដ្ឋានមួយនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាសេនាធិការ។

លេខាធិការដ្ឋាន **គ.ម.ច.** ដឹកនាំដោយប្រធានលេខាធិការដ្ឋានមួយរូបអមដោយអនុប្រធានលេខាធិការដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ម.ច.** ត្រូវកំណត់ដោយប្រកាសរបស់

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាប្រធាន **គ.ម.ច.**។

លេខាធិការដ្ឋាន **គ.ម.ច.** មានមន្ត្រីបម្រើការងារដែលមានស្រាប់មកពីក្របខ័ណ្ឌក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ១០.-**

**គ.ម.ច.** មានសិទ្ធិប្រើត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៥

## ប្រភពធនធាន

**មាត្រា ១១.-**

**គ.ម.ច.** មានប្រភពធនធានផ្គត់ផ្គង់ដោយកញ្ចប់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមូលនិធិដែលទទួលបានមកពីប្រភពហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ព្រមទាំងប្រភពស្របច្បាប់ផ្សេងទៀតសម្រាប់បំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

អនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិនិងជួយជនចាស់ជរានិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ